លេខបញ្ជីពាណិជ្ជកម្ម៖
INV – ១២៧៩ E/២០០៧

# ក្រុមហ៊ុន ប្រេន្តន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី
# (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន
## សម្រាប់រយៈពេល ៩ ខែ គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤

ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន គឺជាការប្រែសំរួលជាភាសាខ្មែរ
ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ
ឯកសារជាភាសាអង់គ្លេសត្រូវបានយកជាគោល។

លេខបញ្ជីពាណិជ្ជកម្ម៖
INV – ១២៧៩ E/២០០៧

# ក្រុមហ៊ុន ប្រេនថ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ១ |
| តារាងតុល្យការសង្ខេប | ២ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប | ៣ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេប | ៤ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេប | ៥ - ៦ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ៧ - ២០ |

BDO

Tel: +855 23 218 128
Fax: +855 23 993 225
www.bdo.com.kh

Suite 28, Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



# របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ជូនចំពោះភាគហ៊ុនិករបស់ ក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា លេខ INV - ១២៧៩ E/២០០៧)

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវ របាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់ ក្រុមហ៊ុន ហ្វ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមាន តារាងតុល្យការសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់រយៈពេល ៩ខែ និងសេចក្តីសង្ខេប កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែម ផ្សេងៗ (ត្រូវបានគេស្គាល់ផងដែរថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបក្នុងគ្រា")។ អគ្គនាយកជាអ្នកទទួលការខុសត្រូវក្នុងការ រៀបចំ និងបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន។ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺ ធ្វើការសន្និដ្ឋានទៅលើ ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដោយផ្អែកលើការត្រួតពិនិត្យឡើងរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាម ស្តង់ដារអន្តរជាតិកម្ពុជាលើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុក្នុងគ្រា ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន"។ ការត្រួតពិនិត្យលើ ព័ត៌មានហិរញ្ញវត្ថុរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការ អនុវត្តនូវ ការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដោយ អនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថា បានដឹងនូវរាល់ បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បាន ប្រសិនបើធ្វើសវនកម្ម។ ដូច្នេះ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះ ទេ។

## សេចក្តីសន្និដ្ឋាន

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថា មិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំ ជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ដែលបានភ្ជាប់មកជាមួយនេះ មិនបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្ត ទាំងអស់ មិនស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា" នោះ ទេ។

ប៊ី ឌី អូ (ខេមបូឌា) លីមីធីត

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៤ វិច្ឆិកា ២០១៤

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

## ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## តារាងតុល្យការសង្ខេប

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្មគិតត្រឹម ថ្ងៃទី៣០ កញ្ញា ២០១៤ | | ធ្វើសវនកម្មរួចគិតត្រឹម ថ្ងៃទី៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ទ្រព្យសកម្ម | | | | | |
| ទ្រព្យសកម្មរយៈពេលវែង | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៥ | ៩.២០៩.៣៣០ | ៣៧.៦២០.១១៣ | ៦.២៤៣.៥៦៧ | ២៤.៩៤៣.០៥០ |
| ទ្រព្យសកម្មអរូបី | | ១០.៩៥៤ | ៤៤.៧៤៧ | ១៣.១២៣ | ៥២.៤២៦ |
| ទ្រព្យសកម្មពន្ធពន្យា | | ១៣១.៩៩៧ | ៥៣៩.២០៧ | ១២២.៧២២ | ៤៩០.២៧៥ |
| | | ៩.៣៥២.២៨១ | ៣៨.២០៤.០៧៦ | ៦.៣៧៩.៤១២ | ២៥.៤៨៥.៧៥១ |
| ទ្រព្យសកម្មរយៈពេលខ្លី | | | | | |
| សន្និធិ | ៦ | ៥.៤៨៤.៤២២ | ២២.៤០៣.៨៦៤ | ៧.៣៥១.៣៦២ | ២៩.៣៦៨.៦៩១ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | ៧ | ៤៤.៣១០.៤៣២ | ១៨១.០០៨.១១៥ | ៣៣.៧១៨.៤១២ | ១៣៤.៧០៥.០៥៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨ | ១៤.៤១០.៦២៤ | ៥៨.៨៦៧.៣៩៩ | ៤២៨.៨៣១ | ១.៧១៣.១៨០ |
| | | ៦៤.២០៥.៤៧៨ | ២៦២.២៧៩.៣៧៨ | ៤១.៤៩៨.៦០៥ | ១៦៥.៧៨៦.៩២៧ |
| ទ្រព្យសកម្មសរុប | | ៧៣.៥៥៧.៧៥៩ | ៣០០.៤៨៣.៤៤៥ | ៤៧.៨៧៨.០១៧ | ១៩១.២៧២.៦៧៨ |
| មូលធន និងបំណុល | | | | | |
| មូលធនរបស់ភាគហ៊ុនិក | | | | | |
| ដើមទុន | ៩ | ១០.០០០.០០០ | ៤០.៨៥០.០០០ | ៨.០០០.០០០ | ៣១.៩៦០.០០០ |
| ភាគហ៊ុនបុព្វលាភ | ១០ | ១៧.២៨០.០០០ | ៧០.៥៨៨.៨០០ | - | - |
| ចំណេញរក្សាទុក | | ៣៥.៥៦៨.៧៣០ | ១៤៥.២៩៨.២៦២ | ៣៣.១៣៣.៦៥១ | ១៣២.៣៦៨.៩៣៦ |
| មូលធនរបស់ភាគហ៊ុនិកសរុប | | ៦២.៨៤៨.៧៣០ | ២៥៦.៧៣៧.០៦២ | ៤១.១៣៣.៦៥១ | ១៦៤.៣២៨.៩៣៦ |
| បំណុល | | | | | |
| បំណុលរយៈពេលខ្លី | | | | | |
| បំណុលផ្សេងៗ | ១១ | ១.៨០១.៨៨៣ | ៧.៣៦០.៦៩២ | ២.០៧៨.២៦២ | ៨.៣០២.៦៥៧ |
| កម្ចី | ១២ | ៤.០០០.០០០ | ១៦.៣៤០.០០០ | ៤៧២.២៦៩ | ១.៨៨៦.៧១៤ |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ៤.៩០៧.១៤៦ | ២០.០៤៥.៦៩១ | ៤.១៩៣.៨៣៥ | ១៦.៧៥៤.៣៧១ |
| | | ១០.៧០៩.០២៩ | ៤៣.៧៤៦.៣៨៣ | ៦.៧៤៤.៣៦៦ | ២៦.៩៤៣.៧៤២ |
| បំណុលសរុប | | ១០.៧០៩.០២៩ | ៤៣.៧៤៦.៣៨៣ | ៦.៧៤៤.៣៦៦ | ២៦.៩៤៣.៧៤២ |
| មូលធនរបស់ភាគហ៊ុនិក និងបំណុលសរុប | | ៧៣.៥៥៧.៧៥៩ | ៣០០.៤៨៣.៤៤៥ | ៤៧.៨៧៨.០១៧ | ១៩១.២៧២.៦៧៨ |

*តារាងតុល្យការសង្ខេបគួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

# ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ គិតត្រឹម ៣០ កញ្ញា ២០១៤(១) | | ៣០ កញ្ញា ២០១៣(២) | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូល | ១៣ | ៤៣.៣៣៧.៦៥៧ | ១៧៧.០៣៤.៣២៩ | ៤៧.២១៨.២៣៦ | ១៩១.៨០០.៤៧៥ |
| ថ្លៃដើម | ១៤ | (៣៥.១២០.១៩៨) | (១៤៣.៤៦៦.០០៩) | (៣៩.៥៣០.១១៩) | (១៦០.៥៧១.៣៤៣) |
| ចំណេញដុល | | ៨.២១៧.៤៥៩ | ៣៣.៥៦៨.៣២០ | ៧.៦៨៨.១១៧ | ៣១.២២៩.១៣២ |
| ចំណូលផ្សេងៗ | ១៥ | ៣៧.០១៣ | ១៥១.១៩៨ | ២.៩០៦ | ១១.៨០៤ |
| ចំណាយរដ្ឋបាល | ១៦ | (៣.៩២៣.៧៩៤) | (១៦.០២៨.៦៩៨) | (២.៥០៧.៦៥២) | (១០.១៨៦.០៨២) |
| ចំណាយលើការដឹកជញ្ជូន | ១៧ | (១.០៨៩.៦៨៧) | (៤.៤៥១.៣៧១) | (១.៩៣៣.១៧០) | (៧.៨៥២.៥៣៧) |
| ចំណាយការប្រាក់ | ១៨ | (៧៣.៥៦០) | (៣០០.៤៩៣) | (៤៤.៥៧២) | (១៨១.០៥១) |
| ចំណាយផ្សេងៗ | | (២៨.៣១៦) | (១១៥.៦៧១) | (២៤.៣៤៧) | (៩៨.៨៩៨) |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ៣.១៣៩.១១៥ | ១២.៨២៣.២៨៥ | ៣.១៨១.២៨២ | ១២.៩២២.៣៦៨ |
| ចំណាយពន្ធ | ១៩ | (៧០៤.០៣៦) | (២.៨៧៥.៩៨៧) | (១.៤៧៧.៣៧៩) | (៦.០០១.១១៣) |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ២.៤៣៥.០៧៩ | ៩.៩៤៧.២៩៨ | ១.៧០៣.៩០៣ | ៦.៩២១.២៥៥ |
| លទ្ធផលផ្សេងៗទៀត បានគិតពន្ធរួច | | - | - | - | - |
| ចំណូលផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | ២.៤៣៥.០៧៩ | ៩.៩៤៧.២៩៨ | ១.៧០៣.៩០៣ | ៦.៩២១.២៥៥ |
| ប្រាក់ចំណូលក្នុងមួយភាគហ៊ុនដែល អាចបែងចែកទៅអ្នកកាន់ភាគហ៊ុន | ២០ | | | | |
| - គោល | | ០.០៧ | ០.០៣ | ០.២១ | ០.៨៧ |
| - ថយចុះ | | ០.០៧ | ០.០៣ | ០.២១ | ០.៨៧ |

## ក្រុមហ៊ុន ប្រ៊ូគ្គន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) អិលអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេប
## សម្រាប់រយៈពេល ៩ខែ គិតត្រឹមថ្ងៃទី៣០ កញ្ញា ២០១៤

| | កំណត់សម្គាល់ | ភាគហ៊ុនដើមទុន | ភាគហ៊ុនបុព្វលាភ | ចំណេញរក្សាទុក | សរុប |
|---|---|---|---|---|---|
| មិនបានធ្វើសវនកម្ម | | | | | |
| **សមតុល្យនាថ្ងៃទី ១ មករា ២០១៤** | | ៨.០០០.០០០ | - | ៣៣.១៣៣.៦៥១ | ៤១.១៣៣.៦៥១ |
| ចំណេញក្នុងការិយបរិច្ឆេទ រួមទាំងចំណូលផ្សេងៗ | | - | - | ២.៤៣៥.០៧៩ | ២.៤៣៥.០៧៩ |
| *ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន* | | | | | |
| ភាគហ៊ុនបោះផ្សាយ | ៩ | ២.០០០.០០០ | ១៧.២៨០.០០០ | - | ១៩.២៨០.០០០ |
| ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនសរុប | | ២.០០០.០០០ | ១៧.២៨០.០០០ | - | ១៩.២៨០.០០០ |
| **សមតុល្យនាថ្ងៃទី ៣០ កញ្ញា ២០១៤** | | ១០.០០០.០០០ | ១៧.២៨០.០០០ | ៣៥.៥៦៨.៧៣០ | ៦២.៨៤៨.៧៣០ |
| *(គិតជាពាន់រៀល)* | | *៤០.៨៥០.០០០* | *៧០.៥៨៨.៨០០* | *១៤៥.២៩៨.២៦២* | *២៥៦.៧៣៧.០៦២* |

*កំណត់សម្គាល់៖*

*(១) របាយការណ៍បម្រែបម្រួលសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានេះ។*

*(២) តួលេខប្រៀបធៀបនៃការិយបរិច្ឆេទមុន មិនបានធ្វើសវនកម្ម ឬពិនិត្យឡើងវិញ ដោយសារតែរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ក្នុងការិយបរិច្ឆេទមុន មិនត្រូវបានរៀបចំឡើង។ ដូចនេះ តួលេខប្រៀបធៀបគឺសម្រាប់ផ្តល់ពត៌មានប៉ុណ្ណោះ។*

# ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៩ខែ គិតត្រឹមថ្ងៃទី៣០ កញ្ញា ២០១៤

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ គិតត្រឹម | | | |
|---|---|---|---|---|---|
| | | ៣០ កញ្ញា ២០១៤[១] | | ៣០ កញ្ញា ២០១៣[២] | |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ៣.១៣៩.១១៥ | ១២.៨២៣.២៨៥ | ៣.១៨១.២៨២ | ១២.៩២២.៣៦៧ |
| និយ័តកម្ម: | | | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ២.១៦៩ | ៨.៨៦០ | ២.៩៦៣ | ១២.០៣៦ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ | ៥ | ៤២៤.៣៩១ | ១.៧៣៣.៦៣៧ | ៣៩១.៩១៧ | ១.៥៩១.៩៦៧ |
| ចំណាយការប្រាក់ | ១៨ | ៧៣.៥៦០ | ៣០០.៤៩៣ | ៤៤.៥៧២ | ១៨១.០៥១ |
| ចំណូលការប្រាក់ | | (១៧. ២៤៦) | (៧០.៤៥០) | (២.៣៤១) | (៩.៥០៩) |
| ការជម្រះចេញពីបញ្ជី | ៥ | ១៥៣.៦៤៩ | ៦២៧.៦៥៦ | - | - |
| ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ៣.៧៧៥.៦៣៨ | ១៥.៤២៣.៤៨១ | ៣.៦១៨.៣៩៣ | ១៤.៦៩៧.៩១២ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | | | |
| សន្និធិ | | ១.៨៦៦.៩៤០ | ៧.៦២៦.៤៥០ | ៧០៥.៧៤៦ | ២.៨៦៦.៧៤០ |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | | (៧. ៨២៦. ៥១៩) | (៣១. ៩៧១. ៣៣០) | (១៥.៤១៨.៦២៥) | (៦២.៦៣០.៤៥៥) |
| គណនីត្រូវបង់ផ្សេងៗ | | (៥៧២. ៧៩៣) | (២. ៣៣៩. ៨៥៩) | ១២.៩០០.៦៩២ | ៥២.៤០២.៦១១ |
| សាច់ប្រាក់(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | | (២. ៧៥៦. ៧៣៤) | (១១. ២៦១. ២៥៨) | ១.៨០៦.២០៦ | ៧.៣៣៦.៨០៨ |
| ការប្រាក់បានបង់ | ១៨ | (៧៣. ៥៦០) | (៣០០. ៤៩៣) | (៤៤.៥៧២) | (១៨១.០៥១) |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ | | (២. ៨៣០. ២៩៤) | (១១. ៥៦១. ៧៥១) | ១.៧៦១.៦៣៤ | ៧.១៥៥.៧៥៧ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| បុរេប្រទាន(អោយ)/ពីភាគីពាក់ព័ន្ធ | | (២.៤៦៩.០៨៧) | (១០.០៨៦.២២០) | ១៥.១១០ | ៦១.៣៧៧ |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (៣. ៥៤៣. ៨០៣) | (១៤. ៤៧៦. ៤៣៥) | (៣៨១.៣៣៣) | (១.៥៤៨.៩៧៥) |
| ចំណូលពីការប្រាក់ | | ១៧.២៤៦ | ៧០.៤៥០ | ២.៣៤១ | ៩.៥០៩ |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (៥. ៩៩៥. ៦៤៤) | (២៤. ៤៩២. ២០៥) | (៣៦៣.៨៨២) | (១.៤៧៨.០៨៩) |

# ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ៩ខែ គិតត្រឹមថ្ងៃទី៣០ កញ្ញា ២០១៤

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម សម្រាប់រយៈពេល ៩ខែ គិតត្រឹម | | | |
|---|---|---|---|---|---|
| | | ៣០ កញ្ញា ២០១៤[១] | | ៣០ កញ្ញា ២០១៣[២] | |
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | | | | | |
| ការបោះផ្សាយភាគហ៊ុនធម្មតា | ៩ | ១៩.២៨០.០០០ | ៧៨.៧៥៨.៨០០ | - | - |
| ការសងប្រាក់កម្ចី | | (៤៧២.២៦៩) | (១. ៩២៩. ២១៩) | (៩៧៨.៨៦៤) | (៣.៩៧៦.១៤៦) |
| ការទទួលយកប្រាក់កម្ចីពីធនាគារ | | ៤.០០០.០០០ | ១៦.៣៤០.០០០ | - | - |
| សាច់ប្រាក់សុទ្ធបានពី/(ប្រើក្នុង)សកម្មភាព ហិរញ្ញប្បទាន | | ២២.៨០៧.៧៣១ | ៩៣.១៦៩.៥៨១ | (៩៧៨.៨៦៤) | (៣.៩៧៦.១៤៦) |
| កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសរុប | | ១៣.៩៨១.៧៩៣ | ៥៧.១១៥.៦២៤ | ៤១៨.៨៨៨ | ១.៧០១.៥២៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | ៤២៨.៨៣១ | ១.៧៥១.៧៧៥ | ៩២០.៣១៨ | ៣.៧៣៨.៣៣២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា | ៨ | ១៤.៤១០.៦២៤ | ៥៨.៨៦៧.៣៩៩ | ១.៣៣៩.២០៦ | ៥.៤៣៩.៨៥៥ |

*កំណត់សម្គាល់៖*

*(១) របាយការណ៍លំហូរសាច់ប្រាក់សង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានេះ។*

*(២) តួរលេខប្រៀបធៀបនៃការិយបរិច្ឆេទមុន មិនបានធ្វើសវនកម្ម ឬពិនិត្យឡើងវិញ ដោយសារតែរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ក្នុងការិយបរិច្ឆេទមុន មិនត្រូវបានរៀបចំឡើង។ ដូចនេះ តួរលេខប្រៀបធៀបគឺសម្រាប់ផ្តល់ពត៌មានប៉ុណ្ណោះ។*

## ក្រុមហ៊ុន ប្រេ្លន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤

### ១. ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមហ៊ុនបានធ្វើវិសោធនកម្មទៅលើការចុះបញ្ជីពាណិជ្ជកម្ម ដើម្បីផ្លាស់ប្តូរទៅជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅលើផ្សារមូលប័ត្រកម្ពុជានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

ទីស្នាក់ការ និងទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន មានក្រុមហ៊ុន ប្រេ្លន ធ្វីន អ៊ិនធើណេសិនណល អិលធីឌី ជាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅ Brithish Virgin Islands ដែលមានទីស្នាក់ការនៅ Portcullis TrusNet (BVI) Limited. Portcullis TrustNet Chambers. P.O. Box ៣៤៤ Road Town. Tortola. British Virgin Islands ជាក្រុមហ៊ុនមេសម្ព័ន្ធ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជារូបិយវត្ថុដុល្លារអាមេរិក ដែលជារូបិយវត្ថុគោលរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តអោយចេញផ្សាយ ដោយនាយកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤។

### ២. សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺការផលិតសំលៀកបំពាក់។ ពុំមានការផ្លាស់ប្តូរជាសារវ័ន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

### ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាមិនត្រូវបានធ្វើសវនកម្ម ហើយត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា*។ របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានេះ គួរតែត្រូវបានអានផ្ទួបផ្សំ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងកំណត់សម្គាល់មួយចំនួនដែលអមជាមួយ។

កំណត់សម្គាល់មួយចំនួន ត្រូវបានជ្រើសរើសដាក់ភ្ជាប់មកជាមួយដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ សម្រាប់ការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន ចាប់គិតពីត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

គោលការណ៍គណនេយ្យ និងវិធីសាស្ត្រនៃការគណនាដែលបានអនុវត្ត គឺសមស្របទៅនឹងគោលការណ៍ និងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៣ លើកលែងតែការអនុវត្តនៃវិសោធនកម្ម និងបំណកស្រាយផ្សេងៗខាងក្រោម៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ ស.រ.ហ.អ.ក ១២ ស.គ.អ.ក ២៧ *សហគ្រាសវិនិយោគ* | ១ មករា ២០១៤ |
| វិសោធនកម្មលើ ស.គ.អ.ក ៣២ *ការកាត់កង ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ* | ១ មករា ២០១៤ |
| វិសោធនកម្មលើ ស.គ.អ.ក ៣៦ *ការលាតត្រដាងទឹកប្រាក់ដែលអាចស្រង់មកវិញ សម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ* | ១ មករា ២០១៤ |
| វិសោធនកម្មលើ ស.គ.អ.ក ៣៩ *សវនកម្មនៃ ដេរីវេទីវ និងការបន្តគណនេយ្យបង្ការលើហានិភ័យ* | ១ មករា ២០១៤ |
| គ.ប.រ.ហ.អ.ក ២១ *ការកំណត់ពន្ធ* | ១ មករា ២០១៤ |

ពុំមានការប៉ះពាល់ជាសារវ័ន្តទៅលើការអនុវត្តនៃវិសោធនកម្ម និងបំណកស្រាយផ្សេងៗក្នុងកំឡុងការិយបរិច្ឆេទនៃគ្រាហិរញ្ញវត្ថុនេះទេ។

ខាងក្រោមនេះ គឺជាស្តង់ដាគណនេយ្យ វិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដែលត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តដោយក្រុមហ៊ុន៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.គ.អ.ក ១៦ ស.គ.អ.ក ២៤ និង ស.គ.អ.ក ៣៨ *បសិដ្ឋកម្មលើ ស.គ.អ (ខួប២០១០ ដល់ ២០១២)* | ១ កក្កដា ២០១៤ |
| វិសោធនកម្មលើ ស.គ.អ.ក ១៩ *ការកំណត់អត្ថប្រយោជន៍នៃផែនការៈ វិភាគទានរបស់បុគ្គលិក* | ១ កក្កដា ២០១៤ |
| វិសោធនកម្មលើ ស.គ.អ.ក ៤០ *បសិដ្ឋកម្មលើ ស.គ.អ.ក (ខួប២០១១ ដល់ ២០១៣)* | ១ កក្កដា ២០១៤ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ២ ស.រ.ហ.អ.ក ៣ និង ស.រ.ហ.អ.ក ៨ *បសិដ្ឋកម្មលើ ស.រ.ហ.អ.ក (ខួប២០១០ ដល់ ២០១២)* | ១ កក្កដា ២០១៤ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ និង ស.រ.ហ.អ.ក ១៣ *បសិដ្ឋកម្មលើ ស.រ.ហ.អ.ក (ខួប២០១១ ដល់ ២០១៣)* | ១ កក្កដា ២០១៤ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ *ភាពចាំបាច់នៃថ្ងៃចូលជាធរមាន របស់ ស.រ.ហ.អ.ក ៩ និង ការបង្ហាញពីអន្តរកាល* | ១ មករា ២០១៥ |
| វិសោធនកម្មលើ ស.គ.អ.ក ១៦ និង ស.គ.អ.ក ៣៨ *ចំណាត់ថ្នាក់នៃវិធីសាស្ត្រដែលអាចទទួលយកបាននៃការរំលស់ទ្រព្យសកម្មរូបី និង អរូបី* | ១ មករា ២០១៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *គណនេយ្យសម្រាប់ការទិញនូវអត្រាការប្រាក់នៅក្នុងប្រតិបត្តិការជារួម* | ១ មករា ២០១៦ |
| ស.រ.ហ.អ.ក ១៤ *បទប្បញ្ញត្តិគណនីពន្យា* | ១ មករា ២០១៦ |
| ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* | ១ មករា ២០១៧ |
| ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ - ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ* | ១ មករា ២០១៨ |

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ក្រុមហ៊ុនកំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងបំណកស្រាយផ្សេងៗ ដោយហេតុថា ផលប៉ះពាល់ទាំងនេះអាចប៉ាន់ស្មានបានសម្រាប់តែការិយបរិច្ឆេទនាពេលអនាគតប៉ុណ្ណោះ។

## ៤. បម្រែបម្រួលតាមរដូវកាល ឬ វដ្តនៃប្រតិបត្តិការអាជីវកម្ម

តម្រូវការសម្រាប់ផលិតផលរបស់ក្រុមហ៊ុន គឺឆាប់នឹងប្រែប្រួលទៅតាមរដូវកាល។ ចំណូល ជាទូទៅមានកំណើនចាប់ពីខែកក្កដា ទៅខែធ្នូ ដែលជាលទ្ធផលនៃការកើនឡើងនូវតម្រូវការសម្រាប់សំលៀកបំពាក់នាសរទរដូវ និងសិសិររដូវ។

## ៩. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីភតិសន្យារយៈពេលវែង ដុល្លារអាមេរិក | សំណង់អាគារ ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៣.៨០២.៤០០ | ១.៣២២.៨៣៥ | - | ៩៩១.៦៤៤ | ៦.៩៧៦ | ១១៩.៧១២ | ៦.២៤៣.៥៦៧ |
| ការទិញបន្ថែម | - | - | ៣.០២២.៧២៧ | ៤៥៤.៦៣៦ | - | ៦៦.៤៤០ | ៣.៥៤៣.៨០៣ |
| ការជម្រះចេញពីបញ្ជី | - | (១៥៣.៦៤៩) | - | - | - | - | (១៥៣.៦៤៩) |
| រំលស់ក្នុងឆ្នាំ | (២៨.៨០០) | (១៧៤.១៣៩) | - | (១៨១.១៤៨) | (១.៣០៨) | (៣៨.៩៩៦) | (៤២៤.៣៩១) |
| **សមតុល្យថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤** | **៣.៧៧៣.៦០០** | **៩៩៥.០៤៧** | **៣.០២២.៧២៧** | **១.២៦៥.១៣២** | **៥.៦៦៨** | **១៤៧.១៥៦** | **៩.២០៩.៣៣០** |
| *(គិតជាពាន់រៀល)* | *១៥.៤១៥.១៥៦* | *៤.០៦៤.៧៦៧* | *១២.៣៤៧.៨៤០* | *៥.១៦៨.០៦៤* | *២៣.១៥៤* | *៦០១.១៣២* | *៣៧.៦២០.១១៣* |

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ដីភតិសន្យារយៈកាលវែងដែលមានតម្លៃចុះបញ្ជីសុទ្ធចំនួន ៣.៧៧៣.៦០០ដុល្លារអាមេរិក (៣១.១២.២០១៣: ៣.៨០២.៤០០ដុល្លារអាមេរិក) ត្រូវបានដាក់តម្កល់នៅធានាគារដើម្បីធានាលើប្រាក់កម្ចីពីធនាគារដល់ក្រុមហ៊ុន (កំណត់សម្គាល់លេខ ១២)។

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីភតិសន្យា រយៈពេលវែង ដុល្លារអាមេរិក | សំណង់អាគារ ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ | ៣.៨៤១.២០០ | ១.៥១២.៣៥០ | ៩៦០.០៥៥ | ៩.៣០១ | ១១៣.៨៦៩ | ៦.៤៣៦.៧៧៥ |
| ការទិញបន្ថែម | - | ៤២.៦៦៨ | ២៨៨.៣២១ | - | ៥៩.១១៨ | ៣៩០.១០៧ |
| រំលស់ក្នុងឆ្នាំ | (៣៨.៨០០) | (២៣២.១៨៥) | (២៥៦.៧៣៣) | (២.៣២៥)) | (៥៣.២៧២) | (៥៨៣.៣១៥) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៣.៨០២.៤០០ | ១.៣២២.៨៣៣ | ៩៩១.៦៤៣ | ៦.៩៧៦ | ១១៩.៧១៥ | ៦.២៤៣.៥៦៧ |
| *(គិតជាពាន់រៀល)* | *១៥.១៩០.៥៨៨* | *៥.២៨៤.៧១៨* | *៣.៩៦១.៦១៤* | *២៧.៨៦៨* | *៤៧៨.២៦២* | *២៤.៩៤៣.០៥០* |

## ៦. សន្និធិ

| | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដើម | | | | |
| វត្ថុធាតុដើម | ១.៦៣៣.៣៦២ | ៦.៦៧២.២៨៤ | ៣.០៤១.៤៨៨ | ១២.១៥០.៧៤៤ |
| ផលិតផលពាក់កណ្ដាលសំរេច | ១.៨៩០.០២៩ | ៧.៧២០.៧៦៨ | ១.៨០៥.៤២៦ | ៧.២១២.៦៧៧ |
| ផលិតផលសំរេច | ១.៩៦១.០៣១ | ៨.០១០.៨១២ | ២.៥០៤.៤៤៨ | ១០.០០៥.២៧០ |
| | ៥.៤៨៤.៤២២ | ២២.៤០៣.៨៦៤ | ៧.៣៥១.៣៦២ | ២៩.៣៦៨.៦៩១ |

## ៧. គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ

| | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| គណនីពាណិជ្ជ | | | | |
| គណនីពាណិជ្ជពីភាគីពាក់ព័ន្ធ | | | | |
| (QMI Industrial Co.. Ltd) | ៤០.៦៤៩.៨២៥ | ១៦៦.០៥៤.៥៣៥ | ៣៣.៣១៥.៣៦០ | ១៣៣.០៩៤.៨៦៣ |
| គណនីត្រូវទទួលផ្សេងៗ | | | | |
| គណនីត្រូវទទួលពីភាគីពាក់ព័ន្ធ | | | | |
| (Success Index Group) | ២.៨០៣.៦២៩ | ១១.៤៥២.៨២៥ | ៣៨.១២៨ | ១៥២.៣២១ |
| គណនីត្រូវទទួលផ្សេងៗ | ៨៥.២៨៧ | ៣៤៨.៣៩៧ | ២.៣៧៨ | ៩.៥០១ |
| អាករលើតម្លៃបន្ថែម | ៦៣៩.៧៨២ | ២.៦១៣.៥០៩ | ១៤២.១៤៩ | ៥៦៧.៨៨៥ |
| កម្ចីនិងគណនីត្រូវទទួល | ៣.៥២៨.៦៩៨ | ១៤.៤១៤.៧៣១ | ១៨២.៦៥៥ | ៧២៩.៧០៧ |
| ចំណាយបង់មុន | ១៣១.៩០៩ | ៥៣៨.៨៤៩ | ២២០.៣៩៧ | ៨៨០.៤៨៦ |
| | ៤៤.៣១០.៤៣២ | ១៨១.០០៨.១១៥ | ៣៣.៧១៨.៤១២ | ១៣៤.៧០៥.០៥៦ |

## ៨. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | មិនបានធ្វើសវនកម្ម<br>គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម<br>គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ៧៧.៥៥២ | ៣១៦.៧៩៩ | ៥០.៨៣៣ | ២៣១.២៣៨ |
| សាច់ប្រាក់នៅធនាគារ | ១៤.៣៣៣.០៧២ | ៥៨.៥៥០.៦០០ | ៣៧៧.៩៩៨ | ១.៤៨១.៩៤២ |
| | ១៤.៤១០.៦២៤ | ៥៨.៨៦៧.៣៩៩ | ៤២៨.៨៣១ | ១.៧១៣.១៨០ |

## ៩. ដើមទុន

| | មិនបានធ្វើសវនកម្ម<br>គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម<br>គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ដុល្លារអាមេរិក | ចំនួនភាគហ៊ុន | ដុល្លារអាមេរិក |
| ភាគហ៊ុនធម្មតា មានតម្លៃ ០.២៥ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន បែងចែកទៅជា | ២០០.០០០.០០០ | ៥០.០០០.០០០ | ២០០.០០០.០០០ | ៥០.០០០.០០០ |
| *(គិតជាពាន់រៀល)* | | ២០៤.២៥០.០០០ | | ១៩៩.៧៥០.០០០ |
| បានបោះផ្សាយនិងបង់រួច គិតត្រឹមថ្ងៃទី ១ មករា | ៣២.០០០.០០០. | ៨.០០០.០០០ | ៣២.០០០.០០០ | ៨.០០០.០០០ |
| បានបោះផ្សាយទៅតាម៖ បោះផ្សាយថ្មី | ៨.០០០.០០០ | ២.០០០.០០០ | | - |
| | ៤០.០០០.០០០ | ១០.០០០.០០០ | ៣២.០០០.០០០ | ៨.០០០.០០០ |
| *(គិតជាពាន់រៀល)* | | *៤០.៨៥០.០០០* | | *៣១.៩៦០.០០០* |

ផ្អបផ្សំជាមួយនឹងការចុះបញ្ជី និងការដាក់តម្លៃ ភាគហ៊ុនរបស់ក្រុមហ៊ុន នៅលើផ្សារមូលបត្រកម្ពុជានៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៤ ក្រុមហ៊ុនបានបោះផ្សាយភាគហ៊ុនធម្មតាចំនួន ១.១២៣.៨១០ ភាគហ៊ុន ក្នុងតម្លៃ ០.២៥ ដុល្លារអាមេរិក ទៅអោយប្រជាជនកម្ពុជាជាសាធារណៈ និង ៦.៨៧៦.១៩០ ភាគហ៊ុន ក្នុងតម្លៃ ០.២៥ ដុល្លារអាមេរិក ទៅអោយភាគហ៊ុននិកដែលបានជ្រើសរើសរួច ដែលមានតម្លៃបោះផ្សាយ ២.៤១ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។

លទ្ធផលនៃការបោះផ្សាយភាគហ៊ុនទាំងនេះ ធ្វើអោយភាគហ៊ុនធម្មតាដែលបានបោះផ្សាយ និងបានបង់ របស់ក្រុមហ៊ុន មានកំណើនរហូតដល់ ១០.០០០.០០០ ដុល្លារអាមេរិក (ស្មើនឹង ៤០.៨៥០.០០០.០០០ រៀល)។

ជាងនេះទៅទៀត ពុំមានការបោះផ្សាយ ការធ្វើមោឃភាព ការទិញ ឬលក់វិញ និងការបង់ឡើងវិញ លើមូលបត្រដើមទុនក្នុងកំឡុងពេលនេះទេ។

## ១០. ភាគហ៊ុនបុព្វលាភ

ភាគហ៊ុនបុព្វលាភ សំដៅលើចំនួនទឹកប្រាក់ដែលក្រុមហ៊ុនលក់លើសពីតម្លៃចារឹកនៃភាគហ៊ុននីមួយៗដែលបានលក់ដូចដែលបានបង្ហាញក្នុងកំណត់សម្គាល់លេខ ៩។

## ១១. គណនីត្រូវបង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| គណនីត្រូវបង់ទៅភាគីពាក់ព័ន្ធ | | | | |
| QMI Industrial Co.. Ltd | ៣១៧.៨៤៦ | ១.២៩៨.៤០១ | ២១.៤៣២ | ៨៥.៦២១ |
| បង្គរ | ១.១២៤.១៣៣ | ៤.៥៩២.០៨៣ | ១.៧៧៧.៥៤១ | ៧.១០១.២៧៦ |
| ពន្ធកាត់ទុក | ៣៥៨.៤៤៣ | ១.៤៦៤.២៤០ | ២៧៧.៩២០ | ១.១១០.២៩១ |
| គណនីត្រូវបង់ផ្សេងៗ | ១.៤៦១ | ៥.៩៦៨ | ១.៣៦៩ | ៥.៤៦៩ |
| | ១.៨០១.៨៨៣ | ៧.៣៦០.៦៩២ | ២.០៧៨.២៦២ | ៨.៣០២.៦៥៧ |

## ១២. កម្ចី

| | មិនបានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣០ កញ្ញា ២០១៤ | | បានធ្វើសវនកម្ម គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៣ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| លក្ខខណ្ឌកម្ចីទី ១ | - | - | ៤២៧.២៦៩ | ១.៨៨៦.៧១៤ |
| លក្ខខណ្ឌកម្ចីទី ២ | ៤.០០០.០០០ | ១៦.៣៤០.០០០ | - | - |
| | ៤.០០០.០០០ | ១៦.៣៤០.០០០ | ៤២៧.២៦៩ | ១.៨៨៦.៧១៤ |

### លក្ខខណ្ឌកម្ចីទី ១ - ៣លានដុល្លារអាមេរិក

យោងតាមកិច្ចសន្យាកម្ចីប្រាក់ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ក្រុមហ៊ុនត្រូវបានផ្តល់នូវកម្ចី ដែលមានទឹកប្រាក់ចំនួន ៣លានដុល្លារអាមេរិក ពីធនាគារពាណិជ្ជទីមួយសាខាភ្នំពេញ។

កម្ចីមានរយៈពេល ៥ឆ្នាំ ហើយរយៈដល់កំណត់គឺ អាស្រ័យទៅលើកាលបរិច្ឆេទដែលបានកំណត់នៅក្នុងលិខិតធានានីមួយៗ។ ការប្រាក់ប្រចាំឆ្នាំគឺ អត្រាការប្រាក់អថេរ ដោយផ្អែកទៅលើ LIBOR រយៈពេល ៦ខែ បូក ៤.៤១%។ អត្រាការប្រាក់ត្រូវបានគណនាលើមូលដ្ឋានចំនួន ៣៦០ថ្ងៃ ក្នុងមួយឆ្នាំ និងថ្លៃបប្រចាំថ្ងៃ ដោយគិតចាប់ពីថ្ងៃដកប្រាក់យកប្រើប្រាស់នូវថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ហើយការប្រាក់នេះត្រូវបង់ប្រចាំខែ។
កម្ចីត្រូវបានធានាដូចខាងក្រោមៈ

ក. លិខិតធានាដោយ លោក សិន យុង មីង (Shen Yung Ming) និង លោក យ៉ាង ស ស៊ីន (Yang Shaw Shin) ។

ខ. ដីភតិសន្យារយៈពេលវែងដែលមានទីតាំងស្ថិតនៅ ភូមិជម្ពូវ័ន្ត ត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (កំណត់សម្គាល់លេខ ៥) និង

គ. គ្រប់ទ្រព្យសកម្មបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនបានសងលក្ខខណ្ឌកម្ចីទី១ អស់នៅខែ ឧសភា ឆ្នាំ២០១៤។

## ១២. កម្ចី (ត)

**លក្ខខណ្ឌកម្ចីទី ២ - ៦.៤លានដុល្លារអាមេរិក**

យោងតាមកិច្ចសន្យាកម្ចីប្រាក់ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ ក្រុមហ៊ុនត្រូវបានផ្តល់នូវកម្ចីរយៈពេលខ្លី ដែលមានទឹកប្រាក់ចំនួន៦.៤លានដុល្លារអាមេរិក (បង្វិល) ពីធនាគារពាណិជ្ជទីមួយសាខាភ្នំពេញ។

កម្ចីមានរយៈពេល ១ឆ្នាំ ហើយរយៈពេលដល់កំណត់គឺ អាស្រ័យទៅលើកាលបរិច្ឆេទដែលបានកំណត់នៅក្នុងលិខិតធានានីមួយៗ។ ការប្រាក់ប្រចាំឆ្នាំគឺ អត្រាការប្រាក់អថេរ ដោយផ្អែកទៅលើ LIBOR រយៈពេល ៦ ខែ បូក ៤.២%។ អត្រាការប្រាក់ត្រូវបានគណនាលើមូលដ្ឋានចំនួន ៣៦០ថ្ងៃ ក្នុងមួយឆ្នាំ ហើយការប្រាក់នេះត្រូវបង់ប្រចាំខែ។

កម្ចីត្រូវបានធានាដូចខាងក្រោមៈ

ក. លិខិតធានាដោយ លោក យ៉ាង ស ស៊ីន (Yang Shaw Shin)

ខ. ដីកម្ចីដំបូង ដែលមានប័ណ្ណសម្គាល់ដីធ្លីលេខ ១២០៥០៥០១-០១១៩ ធ្វើឡើងថ្ងៃទី៩ ខែមេសា ឆ្នាំ ២០១៣ ទីតាំងស្ថិតនៅ ភូមិជម្ពូវ័ន្ត ត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (កំណត់សម្គាល់លេខ ៥) និង

គ. គ្រប់ទ្រព្យសកម្មបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនបានទទួលយកលក្ខខណ្ឌកម្ចីទី២ មានទឹកប្រាក់ចំនួន ៣.៦៤០.០០០ ដុល្លារអាមេរិក នៅក្នុងខែឧសភា ឆ្នាំ២០១៤ និងទឹកប្រាក់ចំនួន ៣៦០.០០០ ដុល្លារអាមេរិក នៅក្នុងខែមិថុនា ឆ្នាំ២០១៤។

## ១៣. ចំណូល

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ការលក់ទំនិញ | ៤២.៨២៧.៩៥៦ | ១៧៤.៩៥២.២០០ | ៤៥.៩២២.៩០៨ | ១៨៦.៥៣៨.៨៥៣ |
| កាត់ ដេរ និងវិចខ្ចប់ | ៧១.០៧៩ | ២៩០.៣៥៨ | ៥៨.៧៩០ | ២៣៨.៨០៥ |
| | ៤៣៨.៦២២ | ១.៧៩១.៧៧១ | ១.២៣៦.៥៣៨ | ៥.០២២.៨១៧ |
| | ៤៣.៣៣៧.៦៥៧ | ១៧៧.០៣៤.៣២៩ | ៤៧.២១៨.២៣៦ | ១៩១.៨០០.៤៧៥ |

## ១៤. ថ្លៃដើម

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| វត្ថុធាតុដើម | ២២.៧៤១.៦៥៩ | ៩២.៨៩៩.៦៧៧ | ២៥.០៤១.៣២៨ | ១០១.៧១៧.៨៧៤ |
| ពលកម្មផ្ទាល់ | ៧.២០២.៣៧៣ | ២៩.៤២១.៦៩៤ | ៧.១១៤.២៦១ | ២៨.៨៩៨.១២៨ |
| ចំណាយផ្សេងៗ | ៥.១៧៦.១៦៦ | ២១.១៤៤.៦៣៨ | ៧.៣៧៤.៥៣០ | ២៩.៩៥៥.៣៤១ |
| | ៣៥.១២០.១៩៨ | ១៤៣.៤៦៦.០០៩ | ៣៩.៥៣០.១១៩ | ១៦០.៥៧១.៣៤៣ |

## ១៥. ចំណូលផ្សេងៗ

| | មិនបានធ្វើសវនកម្ម | | | |
|---|---|---|---|---|
| | រយៈពេល ៩ខែ | | | |
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលការប្រាក់ | ១៧.២៤៦ | ៧០.៤៥០ | ២.៣៤១ | ៩.៥០៩ |
| ចំណូលផ្សេងៗ | ១៩.៧៦៧ | ៨០.៧៤៨ | ៥៦៥ | ២.២៩៥ |
| | ៣៧.០១៣ | ១៥១.១៩៨ | ២.៩០៦ | ១១.៨០៤ |

## ១៦. ចំណាយរដ្ឋបាល

| | មិនបានធ្វើសវនកម្ម | | | |
|---|---|---|---|---|
| | រយៈពេល ៩ខែ | | | |
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយលើការរំលស់ | ៦៩.៩៧៣ | ២៨៥.៨៣៩ | ៦៣.០៥៤ | ២៥៦.១២៥ |
| ចំណាយលើការបរិច្ចាក | ២.៥៩៩ | ១០.៦១៧ | ៥០៤ | ២.០៤៧ |
| ចំណាយលើការកំសាន្ត | ៨.៨៣៩ | ៣៦.១០៧ | ៨.៨៨៥ | ៣៦.០៩១ |
| ចំណាយលើការជួលបរិក្ខារ | ៥.៩៨៥ | ២៤.៤៤៩ | ៥.៩៨៥ | ២៤.៣១១ |
| ចំណាយបុគ្គលិក | ៧៤៦.០២៩ | ៣.០៤៧.៥២៩ | ៦៦៤.៣៨៧ | ២.៦៩៨.៥៧៨ |
| ចំណាយប្រៃសណីយ៍ | ២៧.៩២២ | ១១៤.០៦១ | ៣៥.៥៥០ | ១៤៤.៤០៤ |
| ចំណាយលើអ្នកអាជីព | ១.២៨១.១៩១ | ៥.២៣៣.៦៦៥ | ៥៧.៨៤៣ | ២៣៤.៩៥៨ |
| ចំណាយលើធានារ៉ាប់រងទ្រព្យសកម្ម | ១០.៤៩៩ | ៤២.៨៨៨ | ៤៨៥ | ១.៩៧០ |
| ចំណាយលើការកាត់ចេញនៃទ្រព្យសកម្ម | ១៥៣.៦៤៩ | ៦២៧.៦៥៦ | - | - |
| ចំណាយលើការជួសជុល និងថែរក្សា | ១២.៩៦៥ | ៥២.៩៦២ | ៩.២៨៤ | ៣៧.៧១២ |
| ចំណាយលើស្រាវជ្រាវ និងអភិវឌ្ឍន៍ | ១.០៩៧.៦៧២ | ៤.៤៨៣.៩៩០ | ១.២៨៤.៨០១ | ៥.២១៨.៨៦២ |
| ចំណាយលើសម្ភារៈការិយាល័យ | ៦៣.៦២៤ | ២៥៩.៩០៤ | ៧១.១០២ | ២៨៨.៨១៦ |
| ចំណាយលើការធ្វើដំណើរ | ២០.២១១ | ៨២.៥៦២ | ១៦.១៣៤ | ៦៥.៥៣៦ |
| ចំណាយលើទឹក និងភ្លើង | ២.៧៨០ | ១១.៣៥៦ | ២.១០០ | ៨.៥៣០ |
| ចំណាយផ្សេងៗ | ៤១៩.៨៥៦ | ១.៧១៥.១១៣ | ២៨៧.៥៧៨ | ១.១៦៨.១៤២ |
| | ៣.៩២៣.៧៩៤ | ១៦.០២៨.៦៩៨ | ២.៥០៧.៦៥២ | ១០.១៨៦.០៨២ |

## ១៧. ចំណាយលើការដឹកជញ្ជូន

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដឹកជញ្ជូនចេញ | ២៧៨.៧៥៦ | ១.១៣៨.៧១៨ | ១.១០៦.២៦៣ | ៤.៤៩៣.៦៤០ |
| ថ្លៃពន្ធគយ និងឯកសារ | ៧៦៣.៦៥១ | ៣.១១៩.៥១៤ | ៨២៦.៩០៧ | ៣.៣៥៨.៨៩៧ |
| ឈ្នួលឃ្លាំង | ១៥.០០០ | ៦១.២៧៥ | | |
| ការទិញរបស់របរផ្សេងៗ | ៣២.២៨០ | ១៣១.៨៦៤ | | |
| | **១.០៨៩.៦៨៧** | **៤.៤៥១.៣៧១** | **១.៩៣៣.១៧០** | **៧.៨៥២.៥៣៧** |

## ១៨. ចំណាយហិរញ្ញប្បទាន

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើ៖ កម្ចី | ៧៣.៥៦០ | ៣០០.៤៩៣ | ៤៤.៥៧២ | ១៨១.០៥១ |

## ១៩. ចំណាយពន្ធ

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **ចំណាយពន្ធ** | | | | |
| ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន | ៧១៣.៣១១ | ២.៩១៣.៨៧៥ | ១.៥១៨.៩៣៧ | ៦.១៦៩.៩២២ |
| **ពន្ធពន្យា** | | | | |
| ភាពខុសគ្នាបណ្ដោះអាសន្ន | (៩.២៧៥) | (៣៧.៨៨៨) | (៤១.៥៥៨) | (១៦៨.៨០៩) |
| **ចំណាយពន្ធសរុប** | **៧០៤.០៣៦** | **២.៨៧៥.៩៨៧** | **១.៤៧៧.៣៧៩** | **៦.០០១.១១៣** |

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានការតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (២០១៣:២០%) លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% (២០១៣:១%) នៃចំណូលសរុប ប្រសិនបើមួយណាមានតម្លៃច្រើនជាង។

## ២០. ចំណេញក្នុងមួយភាគហ៊ុន

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណេញសំរាប់ផ្តល់ដល់ ភាគហ៊ុនិកធម្មតា | ២.៨៣៥.០៧៩ | ៩.៩៤៧.២៩៨ | ១.៧០៣.៩០៣ | ៦.៩២១.២៥៥ |
| ចំនួនភាគហ៊ុនធម្មតាដែលបាន ដាក់លក់ គិតជាមធ្យម | ៣២.៦១២.០២២ | ៣២.៦១២.០២២ | ៨.០០០.០០០ | ៨.០០០.០០០ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០.០៧ | ០.៣០ | ០.២១ | ០.៨៧ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ០.០៧ | ០.៣០ | ០.២១ | ០.៨៧ |

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយទូទាត់ចំនួនភាគហ៊ុនធម្មតាដែលមិនទាន់បានដាក់លក់គិតជាមធ្យម ដើម្បីសន្មតការប្រែសម្រួលនៃរាល់ភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃ។

ក្រុមហ៊ុនមិនមានភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃទេក្នុងការិយបរិច្ឆេទនេះ។ ដូច្នេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះមានតម្លៃស្មើ ចំណេញក្នុងមួយភាគហ៊ុនគោល។

## ២១. ប្រតិបត្តិការភាគីពាក់ព័ន្ធ

ក្រុមហ៊ុនមានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម រយៈពេល ៩ខែ | | | |
|---|---|---|---|---|
| | ៣០ កញ្ញា ២០១៤ | | ៣០ កញ្ញា ២០១៣ | |
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ក្រុមហ៊ុនមេសម្ព័ន្ធ | | | | |
| QMI Industrial Co.. Ltd. | | | | |
| លក់ | ៤២.៨២៧.៩៥៥ | ១៧៤.៩៥២.១៩៦ | ៤៥.៩២២.៩០៨ | ១៨៦.៥៣៨.៨៤៥ |
| ទិញ | ១៨.៧៨៩.៦៣៥ | ៧៦.៧៥៥.៦៥៩ | ២២.៩៨៩.៦៩១ | ៩៣.៣៨៤.១២១ |
| ការប្រមូលសាច់ប្រាក់ | ១៦.៧០៣.៨៥៥ | ៦៨.២៣៥.២៤៨ | ២០.០១២.៦៧៩ | ៨១.២៩១.៤៩៩ |
| កាត់កងជាមួយបំណុលពាណិជ្ជកម្ម | ១៨.៧៨៩.៦៣៥ | ៧៦.៧៥៥.៦៥៩ | ១០.៦០២.៩៥៥ | ៤៣.០៦៩.២០២ |
| ការបង់ជំនួស | ៤៤១.៣៧៦ | ១.៨០៣.០២១ | ៣៩១.១៦៤ | ១.៥៩០.២០៨ |
| កាត់កងជាមួយគណនីពាណិជ្ជកម្ម ត្រូវបង់ផ្សេងៗ | ១៤៤.៩៦២ | ៥៩២.១៧០ | ៣៧០.៦៤៥ | ១.៥០៥.៥៦០ |
| ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | | | | |
| Success Index Group | | | | |
| ចំណាយសេវាកម្ម (កាត់ ដេរ និងវិចខ្ចប់) | ៤៤៥.៨០៩ | ១.៨២១.១៣០ | ១.២៣៦.៥៣៨ | ៥.០២២.៨១៧ |
| ការប្រមូលប្រាក់ | ៤៤៥.៨០៩ | ១.៨២១.១៣០ | ១.២៣៦.៥៣៨ | ៥.០២២.៨១៧ |
| ការបង់ជំនួស | ៩៣.៨៤៦ | ៣៨៣.៣៦១ | ៩៣.៨២៩ | ៣៨១.១៣៣ |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | ១២៨.៣៣០ | ៥២៥.៣៣១ | ៩៩.៥៥៧ | ៤០៤.៤០១ |
| បុរេប្រទាន | ២.៧៩៩.៩៨៥ | ១១.៤៣៧.៩៣៩ | - | - |

## ២២. កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគឺ ដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អដែលអាចកើតឡើងដោយសារ ការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

អគ្គនាយកមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃ ការគ្រប់គ្រង់ហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ហេតុនេះគណៈគ្រប់គ្រង បង្កើតគោលការណ៍លម្អិតដូចជា កម្រិតសិទ្ធិអំណាច ត្រួតពិនិត្យការទទួលខុសត្រូវ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយអគ្គនាយក។

### ក. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍ ក្រុមហ៊ុនត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថាក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែលក្រុមហ៊ុនងាយរងផលប៉ះពាល់គឺ តាមរយៈគណនីពាណិជ្ជត្រូវទទួលពីអតិថិជនតែម្នាក់។ អាយុកាលឥណទានរបស់ក្រុមហ៊ុនមានរយៈពេល ៣ខែ ហើយក្រុមហ៊ុនព្យាយាមធ្វើការគ្រប់គ្រងយ៉ាងដិតដល់ លើគណនីត្រូវទទួលដែលមិនទាន់ប្រមូលដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។ សមតុល្យដែលហួសកាលកំណត់ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

### ខ. ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ក្រុមហ៊ុនទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែលក្រុមហ៊ុននឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក្រុមហ៊ុនគ្រប់គ្រងរយៈកាលកំណត់របស់បំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យ សាច់ប្រាក់ងាយស្រួល ក្រុមហ៊ុនធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូល គ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ក្រុមហ៊ុន។

## ២២. កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### គ. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជា ហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនអាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារ ហើយសំខាន់ជាងនេះទៀតគឺ រក្សាអោយបាន ការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចី ដោយប្រុងប្រយ័ត្ន។ ក្រុមហ៊ុនពុំបានប្រើប្រាស់ ដេរីវេទីវ ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

## ២៣. ចំណាយជាប់កិច្ចសន្យា

នៅចុងត្រីមាសនៃការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រុមហ៊ុនបានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មខាងក្រោម៖

| | មិនបានធ្វើសវនកម្ម<br>៣០ កញ្ញា ២០១៤<br>ដុល្លារអាមេរិក | <br><br>គិតជាពាន់រៀល |
|---|---|---|
| គំរោងសាងសង់អាគារ | ១.២៩៥.៤៥៥ | ៥.២៩១.៩៣២ |